# តង្វាយនិងបណ្ដាសាក្នុងសិលាចារឹកប្រាសាទព្រៃថ្នល់ខាងត្បូង K.៤៩១

## ១- ព័ត៌មានទូទៅ

បើយោងតាមឯកសាររបស់លោក **ហ្សក៊ រសដែស** ក្នុងឆ្នាំ១៩៥៣ បញ្ជាក់ថា **ប្រាសាទព្រៃថ្នល់ខាងត្បូង** ជាប្រាសាទឥដ្ឋសម័យមុនអង្គរមួយស្ថិតនៅក្នុងស្រុកពួក តាមបណ្ដោយដងស្ទឹងផ្ទាំង[១]។ ប៉ុន្តែតាមរយៈគេហទំព័រ CISARK បញ្ជាក់ថាប្រាសាទនេះឈ្មោះថា **ប្រាសាទថ្នល់ប្រាសាទ** មានទីតាំងស្ថិតនៅភូមិថ្នល់ ឃុំចារឈូក ស្រុកអង្គរជុំ ខេត្តសៀមរាប ស្ថិតនៅចម្ងាយ៨០០ម៉ែត្រខាងត្បូងគោកប្រាសាទ និងខាងកើតភូមិថ្នល់ទៅវិញ។ គេហទំព័រដដែលនេះ បង្ហាញថាទីនោះមានកសិន្ធុព័ទ្ធជុំវិញ និងមានតួប៉មធ្វើពីឥដ្ឋ បែរមុខទៅកើត មេទ្វារនិងសសរពេជ្រមូលធ្វើពីថ្មភក់។ ប្រាសាទនេះបានរលំបាក់តាំងពីដើមសតវត្សរ៍ទី២០មកម៉្លេះ[២]។

នៅលើមេទ្វារ **ប្រាសាទព្រៃថ្នល់ខាងត្បូង** មានសិលាចារឹកចំនួនពីរផ្ទាំង គឺនៅលើមេទ្វារខាងត្បូង និងមេទ្វារខាងជើង។ អត្ថបទទាំងពីរនេះសរសេរជាភាសាខ្មែរបុរាណសម័យមុនអង្គរ។ នៅលើមេទ្វារខាងត្បូងមានចំនួន១៧បន្ទាត់ មេទ្វារខាងជើងមានចំនួន១៣បន្ទាត់។

អត្ថបទចារឹកនេះ ចារនៅមហាសករាជឆ្នាំ៦០២ ត្រូវនឹងគ្រិស្តសករាជឆ្នាំ៦៨០ ចារអំពីតង្វាយរបស់ «កុរុងមលេង» ដែលជាអភិបាលរបស់ពួកជនជាតិមលេង ថ្វាយចំពោះព្រះគម្ដែងអញស្រីកេទារេស្វរ ដែលជាព្រះនាមម្យ៉ាងទៀតរបស់ព្រះឥសូរ។ ព្រះគម្ដែងស្រីកេទារេស្វរ នៅក្នុងសិលាចារឹកនេះ គឺមានរូបប្រតិមាសិវលិង្គជាតំណាង(សូមមើលរូបក្នុងបញ្ជីរូបភាព)។ នៅមេទ្វារខាងត្បូង មានរាយនាមខ្ញុំបម្រើក្មេងចាស់ប្រុសស្រី និងដីស្រែចម្ការដែលថ្វាយទៅប្រាសាទ។ ចំណែកឯនៅមេទ្វារខាងជើងវិញ គឺជាពាក្យបណ្ដាសាដល់ជនឯណាដែលលួចក្ដី មកសុំក្ដី និងបង្កវិបត្តិក្ដី នៅប្រាសាទរបស់ព្រះស្រីកេទារេស្វរ

[១] Cœdès 1953

[២] https://cisark.mcfa.gov.kh/core/showsite.php?id=525

អត្ថបទដោយ៖ ហ៊ុន ឈុនតេង

នេះ សូមឱ្យអ្នកនោះរួមទាំងញាតិសន្តានធ្លាក់ទៅនរកនិងមហានរក។ នៅខាងចុងអត្ថបទក៏មានបញ្ជាក់អំពីគ្រឿងផ្គត់ផ្គង់បន្ថែមទៀតចំពោះប្រាសាទ និងការចាត់ចែងគ្រឿងទាំងនោះផង។

បើនឹងពិនិត្យលើអក្ខរាវិរុទ្ធក្នុងអត្ថបទនេះវិញ យើងសង្កេតឃើញមានបញ្ហាខ្វះៗ ដែលទំនងជាដោយសារអ្នកចារ ពុំសូវចេះអក្សរបានជ្រៅជ្រះ ជាហេតុនាំឱ្យចារច្រឡំ។ ជាឧទាហរណ៍ពាក្យ «ក្ញុំ» ចារជា «ត្ញុំ» ឯពាក្យ «កុ» ច្រឡំចារជា «ក្ត» ជាដើម។ យ៉ាងនេះក្តីទម្រង់អក្សរក្នុងសិលាចារឹកនេះ មានទម្រង់ស្អាតប្លែកម្យ៉ាង។

## ២- អត្ថបទដើមជាអក្សរខ្មែរទំនើប

### មេទ្វារខាងត្បូង

១- ◎ទ្យ[៣]ត្តរបតិគតគកបរិគ្រហត្រិយោទគីរោចិជេម្ទអនុរាជ

២- នក្បត្រកុរុងឹមលេងឱយិត្ញុំ[៤]តវ្រះកម្រតាងអញ្ញិគ្រីកេ

៣- ទាវេគ្វជ្មហគេវាត្វង៑១វាតតេញ្ញិ១វាតសា១វាត្និតិ១វាតវា

៤- វាតសិរិ១វាតតាង៑១វាកំវញ្ញិ១វាកញ្ជៃ១វាទេហ្វិ១វាបញ្ជមី១

៥- វាសប្តមី១វាបូណ្ណ៌មី៣វារុទ្ធិសារ១វាអកាយ៉្យនិបុណា១វាច

៦- បិមានិ១វាសេញ្ញិ១វាត្មេនិ១វាចបបិហៅ១វាកន្ទតិ១អ្មេមង៑១

៧- កោនិកុ៤កុអ្មេបន្ទេ[៥]១កុក្មោសិ១អ្មេទ្រោង៑កោនិកុ២កុស្រី១

៨- កោនិកុកុចាហ្វិ១កុយេសាយិ១កោនិកុ៣កុយេមាយិ១

៩- កោនិកុ១កុយោង៑កនិ១កោនិក្ត[៦]កុយង៉ាហ្វិ១កុយមា១កោនិ

---

[៣] នៅខាងក្រោម «◌្យ» ត្រូវមានស្រៈ «◌ុ» ប៉ុន្តែដោយសារពុម្ពអក្សរខ្មែរយូនីកូដពុំផ្តល់លទ្ធភាពដល់សំណេរបែបនេះ ទើបពុំអាចបង្ហាញឱ្យឃើញបាន។

[៤] ពាក្យត្រឹមត្រូវគឺ «ក្ញុំ»។

[៥] លោក សេដែស (១៩៥៣) អានជា «បន្ទេ»។

[៦] សំណេរត្រឹមត្រូវជា «កុ»។ អ្នកចារច្រឡំ ចារ «កុ» ទៅជា «ក្ត» វិញ។

អត្ថបទដោយ៖ ហ៊ុន ឈុនតេង

១០- កុ២កុយព្លៀង[7]១កោនិកុ២កុម្ទេំង១កោនិកុ២កុសង្កោ-១

១១- កោនិកុ២កុយជោយិ១កោនិកុ៧·សរ្វបិណ្ឌសវាលវ្ទ្ធគិត្ង[8]

១២- ៤០-១០-៨ត្នុរ១០០ទំរិង១ស្រេមនិជាហ្វិ[9]តគេចិស្រេ(ទុ)ញិលីង្គ

១៣- អំនោយវ្រះកម្រតាងអញិតទៅគិរបុរឱយិតវ្រះស្រេ

១៤- អំរាំលេចិ១ស្រេឱងទ្រៅ១មនិគេសោងក្តិង១ស្រេប្នាកិ

១៥- កុរុងមលេងទៃគិនេះស្រេតពោះគិនេហ្គដោងតេលិ

១៦- កុរុងមលេងឱយិតវ្រះកម្រតាងអញគ្រីកេទា

១៧- វេគ្វរ

## មេទ្វារខាងជើង

១- វ្រះកម្រតាងអញគ្រីកេទាវេគ្វរគេតទងសកិគិមាសិវ្រះ

២- ប្រកិលង្កោសំរិតិចន្ទេកិស្រេទំរិងត្នុរិគេតទងសកិគិគេតទ

៣- ងស្វំទោងអ្នក្កត្វេរិបត្តិវ្រះកម្រតាងអញគ្រីកេទាវេគ្វរពោះ

៤- -(ទៅ)និរយិស្ថានអ្ឋី[10]គេតសិគេតកនិតៃអ្មេគេអ្ដាគេកោនិចៅគេត

៥- បាង--មុតវ្រះចៅលហិកន្ទែលហិកុលេសំវ្យរហារលហិក្ញុំតក្មិត្វេ

៦- មុតិវ្រះលហកតិប្រេគេត្វេងអំរិលហិគិមហានិរយៈនិវន្ទេវផ្ញុំយុ

៧- គលយោៅ៨បវេងអន្ទោង៣ស្វាក្នញិ១[11]--គិត្វៃលុត[12]២ងជើា

៨- ---រិស្វៃសិវុតិចន្ទនកដ្តិ១ល្វោគ្នុំរង្កោត្វោង១អ្នាចិគិទៅកញ្ជ្របិ

៩- --២អ្មេក្មុសិ១កោនិកុ៣អ្មេវាធម្មុករ១កោនិកុ៣អ្មេជុង១ឱ

---

[7] លោក សេដែស (១៩៥៣) អានជា «ឥង»។

[8] ពាក្យត្រឹមត្រូវគឺ «ក្ញុំ»។

[9] លោក សេដែស (១៩៥៣) អានជា «ដោហ្វិ»។

[10] លោក សេដែស (១៩៥៣) អានជា «អ្ឋិ»។

[11] លោក សេដែស (១៩៥៣) ពុំអាន «ក្នញិ១»។

[12] ពាក្យត្រឹមត្រូវជា «លុចិ»។

អត្ថបទដោយៈ ហ៊ុន ឈុនតេង

១០- ត្តរ--វ៉េ-យក្ត១វាបនិហោំមនិចោលិ១សត្រូចំរេនតគិត្ញែវ្រះរង្កោ

១១- ដេកន្ទះគេតជាចមិវ្រះកម្រតាងអញ្រគ្រីកេទារេគ្វរ

១២- --គិនិវន្ទគេចមិវ្រះកម្រតាងអញ្រមុល្យគិចន្ទេកិ---

១៣- លកិគិប្រកិលិងិ------------

## ៣- អត្ថបទប្រែសម្រួល

មហាសករាជឆ្នាំ៦០២ ទី១៣រោច ខែជេស្ឋ នក្សត្រអនុរាធ អភិបាលមលេងថ្វាយខ្ញុំបម្រើចំពោះព្រះគម្តែងអញស្រីកេទារេស្វរ។ ឈ្មោះអ្នកបម្រើទាំងនោះ៖ វាត្ងង១ វាតតេញ១ វាតសា១ វាត្និត ១វាតវា វាតសិរ១ វាតតាង១ វាកំវញ១ វាកញ្ជែ១ វាទេហ្វ១ វាបញ្ចមី១ វាសប្តមី១ វាបូណ្ណមី៣ វាវុទ្ធិសារ១ វាអកាយ៉្យនិបុណា១ វាចបមាន១ វាសេញ១ វាត្មេន១ វាចបបិហោ១ វាកន្ទុត១ អ្មេមង១ កូននាង៤នាក់ កុអ្មេបន្ទេ១ កុក្មោស១ អ្មេទ្រោង កូននាង២នាក់ កុស្រី១ និងកូននាង កុចាហ្វ១ កុយេសាយ១ កូននាង៣នាក់ កុយេមាយ១ កូននាង១នាក់ កុយោងកន១ និងកូននាង កុយងាហ្វ១ កុយមា១ និងកូននាង២នាក់ កុយវៀង១ និងកូននាង២នាក់ កុម្ទេង១និងកូននាង២នាក់ កុសង្កោ១ និងកូននាង២នាក់ កុយងោយ១ និងកូននាង៧នាក់។ សរុបរួមអ្នកបម្រើទាំងក្មេងចាស់៥៨នាក់ គោ១០០ក្បាល ច្បារទ្រើង១។ ស្រែដែលដាវពីគេ ខ្ញីស្រែទិញលិង្គ។ តង្វាយព្រះគម្តែងអញដ៏ស្តេចយាងទៅសិវបូរ (ព្រះបាទជ័យវម៌្មទី១) ថ្វាយចំពោះព្រះ។ ស្រែអំពាំលេច១ ស្រែឱងទ្រៅ១ គឺជាស្រែសងកំដឹង(បំណុល)១។ ស្រែបា្ទក (បានពី)អភិបាលមលេងម្នាក់ទៀត។ ទាំងនេះគឺស្រែដែលអភិបាលមលេងថ្វាចំពោះព្រះគម្តែងអញស្រីកេទារេស្វរ។

ព្រះគម្តែងអញស្រីកេទារេស្វរ។ នរណាដែលលួចមាសព្រះ ប្រាក់ ស្ពាន់ សំរិត សម្លៀក ស្រែ ច្បារទ្រើង គោ គឺអ្នកដែលលួច អ្នកសុំ និងអ្នកធ្វើវិបត្តិចំពោះព្រះគម្តែងអញស្រីកេទារេស្វរ អ្នកទាំងនោះត្រូវធ្លាក់ទៅស្ថាននរក រួមទាំងជីដូនជីតាគេ អ្នកទាំងប្រុសទាំងស្រី ម្តាយគេ ឪពុកគេ កូនចៅគេ។ អ្នកដែលបំបាំងអ្នកដែលបំផ្លាញទាំងនោះ ទាំងចៅក្តី

អត្ថបទដោយ៖ ហ៊ុន ឈុនតេង

ប្រពន្ធក្ដី ក្រុមគ្រួសារគេក្ដីដែលរួមគ្គិតាំក្ដី អ្នកបម្រើក្ដីដែលបំផ្លាញព្រះ សូមឱ្យអ្នកទាំងនោះធ្លាក់ទៅមហានរក។

គ្រឿងផ្គត់ផ្គង់មានៈ សម្លៀកវស្បាគូ៨យៅ ប្រេង៣អណ្ដូង ស្វា៤០០០ ---នៅទិសខាងលិច២ វង្វ---- ស្លែ សិវុត ខ្ទឹមចន្ទន១កដ្ដិ លូ ឃ្មុំ អង្ករ១ត្លោង។ ផ្ដល់អំណាចចាត់ចែងទៅកញ្ញបា។ (អ្នកបម្រើ) --អ្នេក្មុស១ និងកូន៣នាក់ អ្នេវាជម្ទុករ១ និងកូន៣នាក់ អ្នេជុង១ ឧត្តរ--វ៉េ-យក្ដ១ វាបន្ទំមនចោល១។ ការឱ្យទានសម្រាប់ចម្រើនថ្ងៃសីល(គឺ) អង្ករកន្ទះកញ្ជើ។ អ្នកដែលចាំបម្រើព្រះគម្តែងអញស្រីកេទារេសូរ (ជាអ្នកទុកដាក់)គ្រឿងផ្គត់ផ្គង់ទាំងនេះ។ អ្នកដែលចាំបម្រើព្រះគម្តែងអញមុល្យ គឺ(មាន)សម្លៀក----ប្រាក់-តម្ទឹង។

**៤- វាក្យសព្ទ**

| | |
|---|---|
| កុរុង | ស្ដេច, អ្នកគ្រប់គ្រង, អភិបាល។ |
| មលេង | ឈ្មោះជនជាតិមួយពួក។ |
| វា | ពាក្យសម្គាល់អ្នកបម្រើប្រុស។ |
| កុ | ពាក្យសម្គាល់អ្នកបម្រើស្រី។ |
| កុយ | ពាក្យសម្គាល់អ្នកបម្រើស្រីចំណាស់។ |
| កន្ទែ | ស្ត្រី, ភរិយា។ |
| ត្មុរ | គោ។ |
| ទំរិង | ច្បារដំណាំមានច្រើន។ |
| ក្តិង | កំដឹង, បំណុល។ |
| ត្វេ | ធ្វើ។ |

## បញ្ជីឯកសារ


Cœdès, George. (1953). Inscription de Pràsàt Prei Thnăl (Sud). In *Inscription du Cambodge* (Vol. V, pp. 49-52). Paris: Editions de Boccard.


អត្ថបទដោយៈ ហ៊ិន ឈុនតេង

# បញ្ជីរូបភាព



ប្រាសាទព្រៃថ្នល់ (រូបថត៖ EFEO_CAM08261)



ប្រាសាទព្រៃថ្នល់ (រូបថត៖ EFEO_ CAM08262)

អត្ថបទដោយ៖ ហ៊ិន ឈុនតេង



សិវលិង្គរកឃើញនៅប្រាសាទព្រៃថ្នល់ (រូបថតៈ EFEO_ CAM19199-1)

អត្ថបទដោយៈ ហ៊ិន ឈុនតេង



សិលាចារឹកប្រាសាទព្រៃថ្នល់ មេទ្វារខាងត្បូង (រូបថត៖ EFEO_ CAM17112-2)

អត្ថបទដោយ៖ ហ៊ុន ឈុនតេង



សិលាចារឹកប្រាសាទព្រៃថ្នល់ មេទ្វារខាងជើង (រូបថត៖ EFEO_ CAM17112-1)

អត្ថបទដោយ៖ ហ៊ុន ឈុនតេង